# អនុស្សារណៈ

## ស្តីពី

# សហប្រតិបត្តិការកម្មសិទ្ធិខាងបញ្ញា

## រវាង

# ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
# និង ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រថៃ

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ជាភាគីមួយ និង ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រថៃ ជាភាគីម្ខាងទៀត ( ខាងក្រោមហៅកាត់ថាភាគីទាំងពីរ )

**ដោយទទួលស្គាល់** នូវតួនាទីសំខាន់នៃកម្មសិទ្ធិខាងបញ្ញាក្នុងការធ្វើពាណិជ្ជកម្ម និង ការហូរចូលផ្នែកវិនិយោគទុនរបស់ភាគីទាំងពីរ និង សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យកម្មសិទ្ធិខាងបញ្ញាក្នុងតំបន់

**ក្នុងគោលបំណង** ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអោយកាន់តែជិតស្និទ្ធថែមទៀត ក្នុងវិស័យកម្មសិទ្ធិខាងបញ្ញា ដើម្បីផ្តល់នូវមូលដ្ឋានរឹងមាំសំរាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និង ភាពរុងរឿងរបស់ភាគីទាំងពីរ

**ដោយទទួលស្គាល់** នូវសេចក្តីត្រូវការចាំបាច់ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការ និង ការយោគយល់គ្នាទៅវិញទៅមកអោយកាន់តែជិតស្និតថែមទៀត រវាងប្រទេសក្នុងតំបន់ក្នុងវិស័យកម្មសិទ្ធិខាងបញ្ញា ដើម្បីរួមចំណែកបង្កើនថាមភាព និង ភាពលូតលាស់ក្នុងតំបន់

## បានព្រមព្រៀងគ្នាដូចខាងក្រោម :

១_ ជំរុញការទាក់ទងគ្នារវាងស្ថាប័នរបស់ប្រទេសទាំងពីរ ដែលទទួលបន្ទុកខាងកម្មសិទ្ធិខាងបញ្ញារបស់ភាគីទាំងពីរ

២_ ជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស រួមមានការសិក្សាហ្វឹកហ្វឺន និង ការផ្លាស់ប្តូរអ្នកឯកទេសក្នុងវិស័យកម្មសិទ្ធិខាងបញ្ញា ។

៣_ ជំរុញការផ្លាស់ប្តូរ និង ការផ្តល់ព័តមានស្តីពីកម្មសិទ្ធិខាងបញ្ញា ។

៤_ ជំរុញការដោះស្រាយបញ្ហារួមទាំងឡាយទាក់ទងទៅនឹងការគ្រប់គ្រង និង ការការពារកម្មសិទ្ធិខាងបញ្ញា

៥_ ជំរុញការយល់ដឹងជាសាធារណៈអំពីកម្មសិទ្ធិខាងបញ្ញា

៦_ ជំរុញសហប្រតិបត្តិការ និង ពិគ្រោះយោបល់អោយកាន់តែជិតស្និទ្ធថែមទៀតរវាងភាគីទាំងពីរ ដើម្បីផលប្រយោជន៍ទៅវិញទៅមកឈរអង្វែង និង ភាពរុងរឿងជាអមតៈ ។

៧_ ជំរុញការការពារកម្មសិទ្ធិខាងបញ្ញាទៅវិញទៅមករបស់ប្រជាជននៃប្រទេសទាំងពីរ និង

៨_ ធ្វើសកម្មភាពសហប្រតិបត្តិការផ្សេងៗទៀតដែលត្រូវបានកំណត់ដោយភាគីទាំងពីរ ។

## វិស័យសហប្រតិបត្តិការ

១_ ផ្លាស់ប្តូរព័តមាន និង ឯកសាររួមមានទិន្នន័យអេឡិចត្រូនិច

២_ អភិវឌ្ឍន៍ធនធានមនុស្ស

៣_ ផ្លាស់ប្តូរទស្សនៈកិច្ចសិក្សា

៤_ សិក្សាប្រៀបធៀបបែបបទ ការអនុវត្តន៍ជាក់ស្តែង និង ការគ្រប់គ្រងកម្មសិទ្ធិខាងបញ្ញា

៥_ ប្រើប្រាស់ស្វ័យប្រវត្តិកម្មដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការបំរើផលសាធារណៈជនរបស់ប្រទេស នីមួយៗ

៦_ ផ្សព្វផ្សាយនូវពត៏មានស្តីពីកម្មសិទ្ធិខាងបញ្ញា

## ការពិគ្រោះយោបល់

មន្ត្រីទាំងឡាយរបស់ស្ថាប័ននៃភាគីទាំងពីរដែលទទួលខុសត្រូវលើវិស័យកម្មសិទ្ធិខាងបញ្ញា នឹងជួបប្រជុំគ្នាយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ដើម្បីវាយតំលៃការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការក្នុងវិស័យកម្មសិទ្ធិខាងបញ្ញា។ ភាគីទាំងពីរបានពេញចិត្តចំពោះទំនាក់ទំនងជាមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃឡង់ និងសង្ឃឹមថានឹងបង្កើនការយល់យោគគ្នាទៅវិញទៅមក ចំពោះប្រទេសទាំងឡាយក្នុងតំបន់លើវិស័យកម្មសិទ្ធិខាងបញ្ញា ដោយមានទិសដៅពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ។

## ផ្សេងៗ

កិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរនឹងត្រូវបានវាយតំលៃ និង ពិនិត្យឡើងវិញពីពេលមួយទៅពេលមួយទៀត និង ត្រូវបានកែតំរូវ រឺ ពង្រីកបន្ថែមដោយមានការយល់ព្រមរបស់ភាគីទាំងពីរជាមុន តាមរយៈការពិភាក្សាគ្នាជាមិត្តភាព ។

ក្នុងការអនុវត្តន៏កម្មវិធីសហប្រតិបត្តិការ ការគោរពគ្នាទៅវិញទៅមក និង មានផលប្រយោជន៍ទាំងសងខាង គឺជាគោលការណ៍ចំបង ។

អនុស្សរណៈនៃការយោគយល់គ្នាស្តីពីសហប្រតិបត្តិការលើវិស័យកម្មសិទ្ធិខាងបញ្ញា និង ចូលជាធរមានដោយមានការយល់ព្រមពីរដ្ឋាភិបាលនៃភាគីទាំងពីរ ។

ធ្វើនៅទីក្រុងបាងកក. ថ្ងៃទី ០៩ មិនា ឆ្នាំ ១៩៩៧ ជាពីរច្បាប់ដើម ជា ភាសាខ្មែរ ថៃ និង អង់គ្លេស ។ អត្ថបទទាំងបីមានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវបានយកជាគោល ។

| | |
|---|---|
| **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** | **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** |
| **នៃព្រះរាជាណាចក្រកម្ពុជា** | **នៃព្រះរាជាណាចក្រថៃ** |
| **ឯកឧត្តម ចម ប្រសិទ្ធិ** | **ឯកឧត្តម អក្ខរៈ សេនី** |